នស/រកម/១០០៥/០២៨

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នាថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

នស/រកម/១០០៥/០៣៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា ព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

លេខ ៤០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០០៥

**ទីស្តីការគណៈរដ្ឋមន្ត្រី**

... គាន់

## ឧបសម្ព័ន្ធ

## អនុសញ្ញាអន្តរជាតិ ប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង

បណ្តារដ្ឋជាភាគីនៃអនុសញ្ញានេះ

ដោយចងចាំពីគោលបំណងនិងគោលការណ៍ នៃធម្មនុញ្ញអ.ស.ប ពាក់ព័ន្ធនឹងការថែរក្សាសន្តិភាពនិងសុវត្ថិភាពអន្តរជាតិ និងការជំរុញទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋនិងរដ្ឋ

ជាពិសេសដោយរំលឹកឡើងវិញថា បុគ្គលគ្រប់រូបមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់បុគ្គល ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស [២៣] និងអនុសញ្ញាស្តីពីសិទ្ធិស៊ីវិលនិងនយោបាយ [២៤]

ដោយបានអះអាងឡើងវិញនូវសិទ្ធិស្មើភាព និងសិទ្ធិស្វ័យសំរេចរបស់ប្រជាជន ដូចមានចែងក្នុងធម្មនុញ្ញអ.ស.ប និងសេចក្តីថ្លែងការស្តីពីគោលការណ៍ច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងទំនាក់ទំនងជាមិត្តភាពនិងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋនិងរដ្ឋ ស្របតាមធម្មនុញ្ញអ.ស.ប និងសេចក្តីសំរេចចិត្តផ្សេងៗទៀតរបស់មហាសន្និបាត

ដោយយល់ថា ការចាប់ជាចំណាប់ខ្មាំងគឺជាបទល្មើសមួយដែលមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះសហគមន៍អន្តរជាតិ និង ដោយយល់ថា ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ បុគ្គលណាប្រព្រឹត្តអំពើចាប់ជាចំណាប់ខ្មាំង ត្រូវកាត់ទោស ឬធ្វើបត្យាប័ន

ដោយជឿជាក់ថា វាមានការចាំបាច់ជាបន្ទាន់ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងរដ្ឋនិងរដ្ឋ ក្នុងការផ្តល់គំនិតនិងអនុម័តវិធានការប្រសិទ្ធភាព ក្នុងការទប់ស្កាត់ ការកាត់ទោស និងដាក់ទោស ទៅលើរាល់អំពើចាប់ជាចំណាប់ខ្មាំងដូចមានចែងក្នុងអំពើភេរវកម្មដែរ

បានព្រមព្រៀងគ្នាដូចតទៅ:

### មាត្រាទី ១

១. បុគ្គលណាក៏ដោយដែលបានចាប់ ឃុំ និងគំរាមថានឹងសំលាប់ ធ្វើអោយមានរបួស ឬបន្តឃុំខ្លួនបុគ្គលផ្សេងទៀត (ចាប់ពីពេលនេះតទៅហៅថា ជនដែលត្រូវបានចាប់ជាចំណាប់ខ្មាំង) ដើម្បីបង្ខិតបង្ខំភាគីទី៣ ជាពិសេស រដ្ឋ

[23] Resolution 217 A (III)

[24] Resolution 2200 A (XXI), annex.

អង្គការអន្តរជាតិ រដ្ឋាភិបាល រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស មិនអោយធ្វើអំពើអ្វីជាលក្ខខណ្ឌ ឬដោយចេញមុខ ដើម្បីរំដោះជនដែលត្រូវបានចាប់ជាចំណាប់ខ្មាំង ប្រព្រឹត្តបទល្មើសចាប់ជាចំណាប់ខ្មាំង ( " ការចាប់ជាចំណាប់ខ្មាំង " ) ក្នុងអត្ថន័យនៃអនុសញ្ញានេះ ។

២. បុគ្គលណាក៏ដោយដែលៈ

(ក) ប៉ុនប៉ងប្រព្រឹត្តអំពើចាប់ជាចំណាប់ខ្មាំង ឬ

(ខ) ចូលរួមជាចារីជាមួយបុគ្គលមួយផ្សេងទៀត ដែលប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តអំពើចាប់ជាចំណាប់ខ្មាំង

ដូចគ្នានេះដែរប្រព្រឹត្តបទល្មើសមួយ ក្នុងគោលបំណងនៃអនុសញ្ញានេះដែរ ។

## មាត្រា ២

រដ្ឋជាភាគីនីមួយៗ ត្រូវកំណត់បទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា១ អោយទទួលទោសសមស្រប ដោយគិតពីស្ថានទម្ងន់នៃអំពើល្មើសទាំងនោះ ។

## មាត្រា ៣

១. រដ្ឋជាភាគី ដែលជនល្មើសបានឃុំជនដែលបានចាប់ជាចំណាប់ខ្មាំង ក្នុងទឹកដីរបស់ខ្លួន ត្រូវចាត់រាល់វិធានការសមស្រប ដើម្បីបន្ធូរបន្ថយស្ថានការណ៍របស់ជនដែលត្រូវបានចាប់ជាចំណាប់ខ្មាំង ជាពិសេសដើម្បីរំដោះគាត់ចេញ និងបន្ទាប់ពីរំដោះគាត់ ត្រូវជួយសម្រួលដល់ការចាកចេញរបស់គាត់ តាមការចាំបាច់ ។

២. ប្រសិនជាវត្ថុណាមួយដែលជនល្មើសបានរក្សាទុក បន្ទាប់ពីចាប់ជាចំណាប់ខ្មាំង ធ្លាក់ទៅដល់ការកាន់កាប់របស់រដ្ឋជាភាគី រដ្ឋជាភាគីត្រូវបញ្ជូនរបស់នេះជាបន្ទាន់តាមដែលអាចធ្វើបាន ទៅអោយជនដែលត្រូវបានចាប់ជាចំណាប់ខ្មាំង ឬភាគីទី៣ តាមមាត្រា១ ឬទៅអាជ្ញាធរពាក់ព័ន្ធ ។

## មាត្រា ៤

បណ្តារដ្ឋជាភាគីត្រូវរួមសហការក្នុងការទប់ស្កាត់បទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា១ ជាពិសេសៈ

(ក) ចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ការរៀបចំនៅក្នុងទឹកដីរបស់ខ្លួនដើម្បី : ប្រព្រឹត្តបទល្មើសទាំងនោះក្នុង ឬក្រៅពីទឹកដីរបស់ខ្លួន ដោយរួមទាំងវិធានការដើម្បីហាមឃាត់នៅក្នុងទឹកដីរបស់ខ្លួន រាល់អំពើល្មើសនានារបស់បុគ្គល ក្រុម និងអង្គការ ដែលជំរុញ ញុះញង់ រៀបចំ ឬ ទំនាក់ទំនងក្នុងការរៀបចំអំពើចាប់ជាចំណាប់ខ្មាំង ។

(ខ) ផ្លាស់ប្តូរព័ត៌មាន និងសហការចាត់វិធានការរដ្ឋបាលនិងវិធានការផ្សេងៗទៀត ដើម្បីទប់ស្កាត់បទល្មើសទាំងនោះ ។

## មាត្រា ៥

១. រដ្ឋជាភាគីនីមួយៗ ត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនទៅលើរាល់បទល្មើសណាមួយ នៃបទល្មើសទាំងអស់ ដូចមានចែងក្នុងក្នុងមាត្រា១ ដែលបានប្រព្រឹត្ត :

(ក) ក្នុងទឹកដីរបស់ខ្លួន ឬលើនាវា ឬយន្តហោះ ដែលបានចុះបញ្ជីក្នុងរដ្ឋនោះ

(ខ) ដោយបុគ្គលណាមួយដែលមានសញ្ជាតិរដ្ឋខ្លួន ឬប្រសិនបើរដ្ឋនោះយល់ថាវាជាការត្រឹមត្រូវ ដោយបុគ្គលទាំងនោះដែលគ្មានសញ្ជាតិរដ្ឋណាមួយ ដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ក្នុងទឹកដីរបស់ខ្លួន ។

(គ) ដើម្បីបង្ខំរដ្ឋនោះអោយធ្វើ ឬមិនធ្វើអ្វីមួយ ឬ

(ឃ) ចំពោះជនដែលត្រូវបានចាប់ជាចំណាប់ខ្មាំង ដែលមានសញ្ជាតិរដ្ឋនោះ ប្រសិនបើរដ្ឋនោះយល់ថាសមស្រប

២. រដ្ឋជាភាគីនីមួយៗត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រា១ ក្នុងករណីដែលជនល្មើសដែលត្រូវចោទប្រកាន់មានវត្តមានក្នុងទឹកដីរបស់ខ្លួន ហើយខ្លួនមិនបានធ្វើបត្យាប័ន ទៅរដ្ឋណាមួយដែលបានលើកឡើងក្នុងវាក្យខ័ណ្ឌ១ នៃមាត្រានេះ ។

៣. អនុសញ្ញានេះមិនបានដកចេញនូវយុត្តាធិការព្រហ្មទណ្ឌ ដែលប្រតិបត្តិស្របតាមច្បាប់ផ្ទៃក្នុងឡើយ ។

## មាត្រាទី ៦

១. បន្ទាប់ពីយល់ឃើញថា កាលៈទេសៈមានការចាំបាច់ខ្លាំង ៖ រដ្ឋជាភាគីណាមួយដែលមានវត្តមានរបស់ជនល្មើសដែលត្រូវចោទប្រកាន់ នៅក្នុងទឹកដីរបស់ខ្លួន ត្រូវចាប់ឃុំជននោះ ឬចាត់វិធានការណាផ្សេងទៀត ដើម្បីធានាថាវត្តមានរបស់ជននោះគឺក្នុងគោលបំណងដំណើរការក្តីព្រហ្មទណ្ឌ ឬធ្វើបត្យាប័ន ។ រដ្ឋជាភាគីនោះ ត្រូវធ្វើការអង្កេតបឋមទៅលើអង្គហេតុទាំងឡាយ ជាបន្ទាន់ ។

២. ការចាប់ឃុំ ឬវិធានការផ្សេងទៀតដែលបានលើកឡើងក្នុងវាក្យខ័ណ្ឌ១ នៃមាត្រានេះ ត្រូវជូនដំណឹងជាបន្ទាន់ដោយផ្ទាល់ ឬតាមរយៈលោកអគ្គលេខាធិការអ.ស.ប ទៅ ៖

(ក) រដ្ឋដែលបទល្មើសនោះបានកើតឡើង

(ខ) រដ្ឋដែលការបង្ខិតបង្ខំត្រូវបានធ្វើឡើង ឬប៉ុនប៉ង

(គ) រដ្ឋដែលរូបវ័ន្តបុគ្គល ឬនីតិបុគ្គលបានទទួលការបង្ខិតបង្ខំ ឬប៉ុនប៉ង មានសញ្ជាតិរដ្ឋរបស់ខ្លួន

(ឃ) រដ្ឋដែលជនដែលត្រូវបានចាប់ជាចំណាប់ខ្មាំង មានសញ្ជាតិ ឬ ក្នុងទឹកដីដែលនៃរដ្ឋនោះ ដែលគាត់មានលំនៅដ្ឋានអចិន្ត្រៃយ៍

(ង) អង្គការអន្តរជាតិដែលបានទទួលការបង្ខិតបង្ខំ ឬប៉ុនប៉ង

(ច) បណ្តារដ្ឋផ្សេងទៀតពាក់ព័ន្ធ

(ឆ) បុគ្គលណាមួយដែលរងនូវវិធានការទាំងឡាយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ១ នៃមាត្រានេះ ត្រូវមានសិទ្ធិដូចខាងក្រោម ៖

(ក) ទំនាក់ទំនងដោយមិនបង្អង់ជាមួយតំណាងណាមួយដែលនៅជិតបំផុត របស់រដ្ឋដែលខ្លួនមានសញ្ជាតិ ឬខ្លួនមានសិទ្ធិធ្វើទំនាក់ទំនង ឬប្រសិនបើគាត់គ្មានសញ្ជាតិ រដ្ឋដែលក្នុងនោះគាត់មានលំនៅដ្ឋានអចិន្ត្រៃយ៍ ។

(ខ) អោយតំណាងរដ្ឋនោះចូលជួប

៤. សិទ្ធិទាំងឡាយដែលបានលើកឡើងក្នុងវាក្យខ័ណ្ឌ៣ នៃមាត្រានេះ ត្រូវអនុវត្តស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋ ដែលជនល្មើសត្រូវចោទប្រកាន់មានវត្តមាន។ ទោះជាយ៉ាងណាក៏ដោយ អាស្រ័យទៅតាមលក្ខខណ្ឌដែលថាច្បាប់និងបទប្បញ្ញត្តិដូចពោលខាងលើ ត្រូវផ្តល់សុពលភាពពេញលេញ ចំពោះគោលបំណងដែលបានផ្តល់សិទ្ធិតាមវាក្យខ័ណ្ឌ៣ នៃមាត្រានេះ ក៏ត្រូវការផងដែរ។

៥. បទប្បញ្ញត្តិវាក្យខ័ណ្ឌ៣ និង៤ នៃមាត្រានេះ ដោយមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋណាមួយដែលមានយុត្តាធិការ ស្របតាមវាក្យខ័ណ្ឌ១ (ខ) នៃមាត្រា៥ នេះ ត្រូវអញ្ជើញគណៈកម្មាធិការកាកបាតក្រហមអន្តរជាតិអោយទំនាក់ទំនងជាមួយ និងចូលជួបជនល្មើសដែលត្រូវចោទប្រកាន់។

៦. រដ្ឋដែលបានធ្វើអង្កេតបឋមដូចបានលើកឡើងក្នុងវាក្យខ័ណ្ឌ១ នៃមាត្រានេះ ត្រូវរបាយការណ៍ពីលទ្ធផលជាបន្ទាន់ ទៅបណ្តារដ្ឋ ឬ អង្គការដែលបានលើកឡើងក្នុងវាក្យខ័ណ្ឌ២ នៃមាត្រានេះ និងចង្អុលបង្ហាញតើខ្លួនចង់អនុវត្តយុត្តាធិការរបស់ខ្លួនឬអត់។

## មាត្រាទី ៧

រដ្ឋជាភាគីដែលជនល្មើសត្រូវចោទប្រកាន់ ត្រូវបានកាត់ទោសក្នុងរដ្ឋរបស់ខ្លួន ត្រូវផ្តល់លទ្ធផលចុងក្រោយនៃដំណើរការក្តី ស្របតាមច្បាប់ផ្ទៃក្នុងរបស់ខ្លួន ទៅអោយលោកអគ្គលេខាអ.ស.ប ដែលលោកត្រូវបញ្ជូនពត៌មាននេះទៅបណ្តារដ្ឋ អង្គការអន្តរជាតិរដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀត។

## មាត្រាទី ៨

១. រដ្ឋជាភាគីដែលជនល្មើសត្រូវចោទប្រកាន់ ត្រូវបានរកឃើញក្នុងទឹកដីរបស់ខ្លួន ប្រសិនបើខ្លួនសំរេចថាធ្វើបត្យាប័នជននោះ ត្រូវមានកាតព្វកិច្ច និងដោយគ្មានការលើកលែង និង ទោះបីជាបទល្មើសនេះបានប្រព្រឹត្តឡើងក្នុងទឹកដីរបស់ខ្លួនឬអត់ក៏ដោយ ដាក់សំណុំរឿងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីកាត់ទោស តាមនីតិវិធីស្របតាមច្បាប់របស់រដ្ឋនោះ។ អាជ្ញាធរទាំងនោះត្រូវចេញសេចក្តីសំរេចចិត្តដូចគ្នានឹងករណីបទល្មើសធម្មតាណាមួយដែលមានស្ថានទំងន់ធ្ងន់ធ្ងរ តាមច្បាប់របស់រដ្ឋនោះ។

២. បុគ្គលណាក៏ដោយដែលកំពុងស្ថិតក្នុងដំណើរការក្តី ពាក់ព័ន្ធនឹងបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា១ ត្រូវធានានូវការកាត់ក្តីមួយប្រកបដោយយុត្តិធម៌ នៅគ្រប់ដំណាក់កាលទាំងអស់ នៃដំណើរការក្តី រួមទាំងការទទួលបាននូវសិទ្ធិ តាមច្បាប់របស់រដ្ឋ ក្នុងទឹកដីដែលជននោះមានវត្តមាន។

## មាត្រាទី ៩

១. ស្របតាមអនុសញ្ញានេះ សំណើសុំអោយធ្វើបត្យាប័នជនល្មើសដែលត្រូវចោទប្រកាន់ មិនត្រូវផ្តល់ជូនឡើយ ប្រសិនបើរដ្ឋដាក់ពាក្យស្នើ មានហេតុផលគ្រប់គ្រាន់ ដើម្បីជឿថា:

(ក) សំណើសុំអោយធ្វើបត្យាប័ន ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា១ ត្រូវបានធ្វើឡើងក្នុងការកាត់ទោស ឬដាក់ទោស បុគ្គលម្នាក់ដោយហេតុផលជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិពន្ធ ឬគំនិតនយោបាយ ឬ

(ខ) អាចនឹងប៉ះពាល់ដល់ឋានៈរបស់បុគ្គលនោះ

(១) ដោយហេតុផលណាមួយដែលមានចែងក្នុងអនុវាក្យខ័ណ្ឌ (ក) នៃវាក្យខ័ណ្ឌនេះ ឬ

(២) ដោយហេតុផលណាមួយ ដែលថាការទំនាក់ទំនងរបស់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ មិនអាចធ្វើបាន ជាមួយបុគ្គលនោះ ។

២. ចំពោះបទល្មើសទាំងឡាយដែលមានចែងក្នុងអនុសញ្ញានេះ បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញា ស្តីពីការធ្វើបត្យាប័ន រវាងរដ្ឋនិងរដ្ឋ ត្រូវកែប្រែរវាងរដ្ឋជាភាគី ក្នុងករណីដែលថា បទប្បញ្ញត្តិទាំងនោះមិនជំទាស់នឹងអនុសញ្ញានេះ ។

## មាត្រាទី ១០

១. បទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រាទី១ ត្រូវចាត់ទុកថាត្រូវបញ្ចូលជាបទល្មើសដែលត្រូវធ្វើបត្យាប័ន ក្នុងសន្ធិសញ្ញាណាមួយ ដែលកំពុងមានសុពលភាពរវាងបណ្តារដ្ឋជាភាគី ។ រដ្ឋជាភាគីមានភារកិច្ចបញ្ចូលបទល្មើសទាំងនេះជាបទល្មើសដែលត្រូវធ្វើបត្យាប័ន ក្នុងរាល់សន្ធិសញ្ញាស្តីពីបត្យាប័ន ដែលត្រូវធ្វើរវាងរដ្ឋទាំងនោះ ។

២. ប្រសិនបើរដ្ឋជាភាគីមួយ ដែលកំណត់ការធ្វើបត្យាប័ន ជាលក្ខខណ្ឌតាមអត្ថិភាពនៃសន្ធិសញ្ញា បានទទួលសំណើសុំធ្វើបត្យាប័នពីរដ្ឋម្ខាងទៀត ដែលខ្លួនមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយ រដ្ឋដែលដាក់ពាក្យស្នើអាចគិតពិចារណាតាមជំរើសរបស់ខ្លួន ទៅលើអនុសញ្ញានេះ ថាជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័ន ចំពោះបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា១ ។ ការធ្វើបត្យាប័នត្រូវអាស្រ័យទៅតាមលក្ខខណ្ឌផ្សេងទៀត ដែលមានចែងក្នុងច្បាប់ផ្ទៃក្នុង របស់រដ្ឋដាក់ពាក្យស្នើសុំ ។

៣. បណ្តារដ្ឋជាភាគីដែលមិនកំណត់ការធ្វើបត្យាប័ន តាមលក្ខខណ្ឌអត្ថិភាពសន្ធិសញ្ញាទេ ត្រូវទទួលស្គាល់បទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា១ ថាជាបទល្មើសដែលត្រូវធ្វើបត្យាប័ន រវាងរដ្ឋទាំងនោះ អាស្រ័យទៅតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ផ្ទៃក្នុងរបស់រដ្ឋដាក់ពាក្យស្នើសុំ ។

៤. បទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា១ សំរាប់គោលបំណងនៃការធ្វើបត្យាប័ន ត្រូវចាត់ទុកថាវាហាក់ដូចជាបានកើតឡើង មិនត្រឹមតែក្នុងទីកន្លែងដែលបទល្មើសបានកើតឡើងនោះទេ ប៉ុន្តែថែមទាំងក្នុងទឹកដីរបស់បណ្តារដ្ឋដែលតំរូវអោយបង្កើតយុត្តាធិការ ស្របតាមវាក្យខ័ណ្ឌ១ មាត្រា៥ ។

## មាត្រាទី ១១

១. បណ្តារដ្ឋជាភាគីត្រូវផ្តល់នូវវិធានការជំនួយអោយគ្នាអោយបានខ្លាំងក្លាបំផុត ពាក់ព័ន្ធនឹងដំណើរការក្តីព្រហ្មទណ្ឌ ដែលបានធ្វើឡើងចំពោះបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា១ រួមទាំងការផ្តល់នូវរាល់ភ័ស្តុតាងតាមលទ្ធភាពរបស់ខ្លួន ដែលចាំបាច់ សំរាប់ដំណើរការក្តី ។

២. បទប្បញ្ញត្តិទាំងឡាយវាក្យខ័ណ្ឌ១ នៃមាត្រានេះ មិនត្រូវប៉ះពាល់ដល់កាតព្វកិច្ចទាំងឡាយ ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមក ដែលមានចែងក្នុងសន្ធិសញ្ញាផ្សេងៗទៀតឡើយ ។

## មាត្រានី ១២

ដោយអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ស្តីពីការការពារជនរងគ្រោះដោយសារសង្គ្រាម[២៥] ឬពិធីសារបន្ថែមចំពោះអនុសញ្ញាទាំងនោះ ត្រូវអនុវត្តចំពោះអំពើដោយឡែកមួយនៃការចាប់ជាចំណាប់ខ្មាំង និងដោយបណ្តារដ្ឋជាភាគីនៃអនុសញ្ញានេះ មានកាតព្វកិច្ចស្របតាមអនុសញ្ញាទាំងនោះ ក្នុងការកាត់ទោស ឬប្រគល់ជនដែលចាប់ចំណាប់ខ្មាំង អនុសញ្ញានេះមិនត្រូវអនុវត្តចំពោះអំពើចាប់ជាចំណាប់ខ្មាំង ដែលបានប្រព្រឹត្តឡើងក្នុងកំឡុងពេលជំលោះដោយអាវុធដូចមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងពិធីសារបន្ថែមឡើយ រួមទាំងជំលោះដោយអាវុធដូចមានចែងក្នុងមាត្រា១ វាក្យខ័ណ្ឌ៤ នៃពិធីសារបន្ថែម១ ឆ្នាំ ១៩៧៧[២៧] ដែលក្នុងពេលនោះមនុស្សកំពុងប្រយុទ្ធប្រឆាំងនឹងអាណានិគមនិយម និងការកាន់កាប់ដោយបរទេស និងប្រឆាំងនឹងរបបជាតិសាសន៍ ក្នុងការប្រើប្រាស់សិទ្ធិស្វ័យសំរេចរបស់ពួកគេ ដូចមានចែងក្នុងធម្មនុញ្ញអ.ស.ប និងសេចក្តីថ្លែងការណ៍ជាសាកលអំពីគោលការណ៍នៃច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងទំនាក់ទំនងជាមិត្តភាព ក្នុងចំណោមរដ្ឋនិងរដ្ឋ ស្របតាមធម្មនុញ្ញរបស់អ.ស.ប ។

## មាត្រានី ១៣

អនុសញ្ញានេះមិនត្រូវអនុវត្ត នៅទីណាដែលអំពើល្មើសមួយត្រូវបានកើតឡើងនៅក្នុងរដ្ឋមួយ ដែលជនត្រូវបានចាប់ជាចំណាប់ខ្មាំង និងជនល្មើសត្រូវចោទប្រកាន់ មានសញ្ជាតិរដ្ឋនោះ ហើយជនល្មើសដែលត្រូវចោទប្រកាន់ត្រូវបានរកឃើញនៅក្នុងរដ្ឋនោះ ។

## មាត្រានី ១៤

គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ មានន័យបញ្ជាក់ពីការរំលោភដល់បូរណភាពទឹកដី ឬឯករាជ្យភាពនយោបាយរបស់រដ្ឋមួយ ផ្ទុយនឹងធម្មនុញ្ញរបស់អ.ស.ប ឡើយ ។

## មាត្រានី ១៥

បទប្បញ្ញត្តិនៃអនុសញ្ញានេះ មិនត្រូវប៉ះពាល់ដល់សន្ធិសញ្ញាស្តីពីការសុំសិទ្ធជ្រកកោណ រវាងរដ្ឋដែលជាភាគីចំពោះអនុសញ្ញាទាំងនោះ ដែលមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការអនុម័តអនុសញ្ញានេះ ។ ប៉ុន្តែរដ្ឋជាភាគីមួយចំពោះអនុសញ្ញានេះ មិនអាចប្រើប្រាស់សន្ធិសញ្ញាទាំងនោះ ចំពោះរដ្ឋជាភាគីម្ខាងទៀតចំពោះអនុសញ្ញានេះ ដែលមិនមែនជាភាគីចំពោះសន្ធិសញ្ញាទាំងនោះ ។

## មាត្រានី ១៦

១. រាល់ជំលោះរវាងរដ្ឋជាភាគី២ ឬច្រើន ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានតាមការចរចា ត្រូវដាក់ស្នើរកមជ្ឈត្តករ តាមសំណើសុំរបស់ភាគីមួយ ក្នុងចំណោមភាគីទាំងពីរ ។ ប្រសិនបើក្នុងរយៈពេល៦ខែ គិតចាប់កាលបរិច្ឆេទនៃការដាក់ពាក្យរកមជ្ឈត្តករ ភាគីទាំងពីរមិនអាចព្រមព្រៀងគ្នា

[25] United Nations, Treaty Series, vol. 75, Nos. 970-973
[27] A/32/144, annex I.

ក្នុងការបង្កើតមជ្ឈត្តការ ភាគីមួយក្នុងចំណោមភាគីទាំងពីរ អាចដាក់ពាក្យស្នើសុំជំលោះនេះទៅតុលាការយុត្តិធម៌អន្តរជាតិ ស្របតាមលក្ខន្តិកៈរបស់តុលាការ ។

២. រាល់ពេលនៃការចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬចូលជាភាគីនៃអនុសញ្ញានេះ រដ្ឋជាភាគីនីមួយៗអាចប្រកាសថា ខ្លួនមិនជាប់កាតព្វកិច្ចចំពោះវាក្យខ័ណ្ឌ១ នៃមាត្រានេះ ។ បណ្តារដ្ឋជាភាគីផ្សេងៗទៀត មិនត្រូវជាប់កាតព្វកិច្ចចំពោះវាក្យខ័ណ្ឌ១ នៃមាត្រានេះ ចំពោះរដ្ឋជាភាគីណាមួយដែលបានដាក់លក្ខខណ្ឌបែបនេះ ។

៣. រដ្ឋជាភាគីណាមួយដែលបានដាក់លក្ខខណ្ឌស្របតាមវាក្យខ័ណ្ឌ២ នៃមាត្រានេះ អាចដកលក្ខខណ្ឌនោះបានគ្រប់ពេលទាំងអស់ តាមរយៈការជូនដំណឹងទៅលោកអគ្គលេខាធិការអ.ស.ប ។

## មាត្រានី ១៧

១. អនុសញ្ញានេះបើកចំហរសំរាប់ហត្ថលេខាពីបណ្តារដ្ឋទាំងអស់ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨០ នៅឯទីស្នាក់ការអ.ស.ប នៅក្រុងញូយ៉ក ។

២. អនុសញ្ញានេះត្រូវដាក់សុំសច្ចាប័ន ។ លិខិតូបករណ៍ផ្តល់សច្ចាប័ន ឬចូលជាសមាជិក ត្រូវដាក់តំកល់នៅឯអគ្គលេខាធិការដ្ឋានអ.ស.ប ។

## មាត្រានី ១៨

១. អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី ៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ឬចូលជាសមាជិកទី២២ នៅឯអគ្គលេខាធិការដ្ឋានអ.ស.ប ។

២. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ឬចូលជាភាគីចំពោះអនុសញ្ញានេះ បន្ទាប់ពីការតំកល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ឬចូលជាភាគី ទី២២ អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីរដ្ឋនោះបានដាក់លិខិតូបករណ៍ផ្តល់សច្ចាប័ន ឬចូលជាភាគី ។

## មាត្រានី ១៩

១. រដ្ឋជាភាគីណាមួយក៏ដោយអាចប្រកាសបដិសេធអនុសញ្ញានេះ តាមរយៈលិខិតជូនដំណឹងជាផ្លូវការចំពោះលោកអគ្គលេខាធិការអ.ស.ប ។

២. សេចក្តីប្រកាសបដិសេធត្រូវចូលជាធរមានរយៈពេល១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលលោកអគ្គលេខាធិការបានទទួលលិខិតជូនដំណឹង ។

## មាត្រានី ២០

អត្ថបទដើមនៃអនុសញ្ញានេះ ដែលអត្ថបទនេះជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញមានសុពលភាពដូចគ្នា ត្រូវដាក់តំកល់ជាមួយលោកអគ្គលេខាធិការអ.ស.ប ដែលលោកត្រូវបញ្ជូនអត្ថបទថតចំលងដោយមានការបញ្ជាក់ផងនោះ ទៅគ្រប់បណ្តារដ្ឋទាំងអស់ ។

ដើម្បីជាសក្ខីភាព អ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលសិទ្ធិស្របច្បាប់ពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ដែលបានបើកចំហរសំរាប់ហត្ថលេខានៅក្រុងញូយ៉ក នៅថ្ងៃទី.......[២២]

## ៣៤/១៨៧ របាយការណ៍របស់គណៈកម្មាធិការពិសេស ទទួលបន្ទុកធម្មនុញ្ញរបស់អ.ស.ប និងពង្រឹងតួនាទីរបស់អ.ស.ប

មហាសន្និបាត

ដោយអះអាងសារជាថ្មី នូវការគាំទ្ររបស់ខ្លួនចំពោះគោលបំណងនិងគោលការណ៍ ដែលមានចែងក្នុងធម្មនុញ្ញរបស់អ.ស.ប

ដោយរំលឹកឡើងវិញនូវសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ៩៩២ (X) ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៥៥ លេខ២២៨៥ ( XXII) ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៦៧ លេខ ២៥៥២ ( XXIV) ចុះថ្ងៃទី ១២ ធ្នូ ១៩៦៩ លេខ ២៦៩៧ ( XXV) ចុះថ្ងៃទី១១ ធ្នូ ១៩៧០ លេខ ២៩៦៨ ( XXVII) ចុះថ្ងៃទី ១៤ ធ្នូ ១៩៧២ និងលេខ ៣៣៤៩ ( XXIX) ចុះថ្ងៃទី ១៧ ធ្នូ ១៩៧៤

ដោយរំលឹកឡើងវិញផងដែរនូវសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ២៩២៥ ( XXVII) ចុះថ្ងៃទី ២៧ វិច្ឆិកា ១៩៧២ លេខ ៣០៧៣ ( XXVII) ចុះថ្ងៃទី ៣០ វិច្ឆិកា ១៩៧៣ និងលេខ ៣២៨២ ( XXVIII) ចុះថ្ងៃទី ១២ ធ្នូ ១៩៧៤ ស្តីពីការពង្រឹងតួនាទីរបស់អ.ស.ប

ដោយរំលឹកឡើងវិញជាពិសេសនូវសេចក្តីសំរេចចិត្តរបស់ខ្លួន លេខ ៣៤៩៩ ( XXX) ចុះថ្ងៃទី ១៥ ធ្នូ ១៩៧៥ ដែលបានបង្កើតគណៈកម្មាធិការពិសេសទទួលបន្ទុកធម្មនុញ្ញអ.ស.ប និងពង្រឹងតួនាទីរបស់ អ.ស.ប និងសេចក្តីសំរេចចិត្តលេខ ៣១/២៨ ចុះថ្ងៃទី ២៩ វិច្ឆិកា ១៩៧៦ លេខ ៣២/៤៥ ចុះថ្ងៃទី ៨ ធ្នូ ១៩៧៧ និងលេខ ៣៣/៩៤ ចុះថ្ងៃទី ១៦ ធ្នូ ១៩៧៨

ដោយបានពិចារណានូវរបាយការណ៍របស់គណៈកម្មាធិការពិសេស[២៣]

ដោយកត់សំគាល់នូវការរីកចំរើន ក្នុងការបំពេញអាណត្តិរបស់គណៈកម្មាធិការពិសេស

ដោយរំលឹកឡើងវិញនូវសេចក្តីសំរេចចិត្តរបស់ខ្លួន ដែលត្រូវបានអនុម័តនៅសម័យប្រជុំពេញអង្គលើកទី៤ ថ្ងៃ ទី ២១ កញ្ញា ១៩៧៩ ដើម្បីបញ្ចូលក្នុងរបៀបវារៈលើកទី៣៤ នូវប្រធានបទ " ដំណោះស្រាយជំលោះដោយសន្តិវិធីរវាងរដ្ឋនិងរដ្ឋ"

[22] The Convention was opened for signature on 18 December 1979.
[23] Official Records of the General Assembly, Thirty-fourth Session, Supplement No. 33 (A/34/33)

ដោយកត់សំគាល់ពីសារៈសំខាន់នៃការពិគ្រោះយោបល់នៅមុនសម័យប្រជុំ រវាងសមាជិកនៃគណៈកម្មាធិការពិសេស និងរដ្ឋពាក់ព័ន្ធដ៏ទៃទៀត អាចមានក្នុងការសំរួលដល់ការអនុវត្តភារកិច្ចរបស់ខ្លួន

ដោយយល់ឃើញថា គណៈកម្មាធិការពិសេសមិនទាន់បានបញ្ចប់អាណត្តិដែលបានប្រគល់ជូន

១. កត់ត្រាទុកនូវរបាយការណ៍របស់គណៈកម្មាធិការពិសេស ទទួលបន្ទុកធម្មនុញ្ញអ.ស.ប និងពង្រឹងតួនាទីរបស់ អ.ស.ប

២. សំរេចថា គណៈកម្មាធិការពិសេសម គួរបន្តការងាររបស់ខ្លួន ស្របតាមភារកិច្ចដែលបានប្រគល់ជូនដូចខាងក្រោម :

(ក) ធ្វើបញ្ជីសំណើដែលបានធ្វើឡើង ឬដែលនឹងធ្វើនៅក្នុងគណៈកម្មាធិការ និងកំណត់សំណើទាំងនោះដែលស្តែងអោយឃើញនូវការចាប់អារម្មណ៍ពិសេស ។